មជ្ឈមណ្ឌលឯកសារកម្ពុជា

# ជនជាប់ចោទ អៀង សារី ច្រានចោលការធ្វើសក្ខីកម្ម

នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១១ ជនជាប់ចោទ អៀង សារី ដែលជាអតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ បានជូនសេចក្តីជូនដំណឹងមួយដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ នៅក្នុងសេចក្តីជូនដំណឹងនេះ ជនជាប់ចោទ អៀង សារី បានបញ្ជាក់ពីគោលជំហរនិង ចេតនារបស់ខ្លួនក្នុងការច្រានចោលការធ្វើសក្ខីកម្ម រួមទាំងការឆ្លើយតបទៅនឹងសំណួរណាមួយក្នុងអំឡុងពេលសវនាការ ឬសវនាការជាដំណាក់កាលៗ នៅក្នុងសំណុំរឿង ០០២ ។ អតីតឧបនាយករដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យរូបនេះ បានបញ្ជាក់នៅក្នុងសេចក្តីជូនដំណឹងថា ខ្លួនបានយល់ដឹងយ៉ាងពេញលេញអំពីដំណើរការនីតិវិធីប្រឆាំងនឹងខ្លួនច្បាស់ ហើយអះអាងថានឹងប្រគល់សិទ្ធឲ្យទៅសហមេធាវីរបស់ខ្លួន នៅពេលមានសវនាការក្នុងការតំណាង និងការពារក្តីដើម្បីធានាការអនុវត្តដ៏មានប្រសិទ្ធភាពនូវសិទ្ធរបស់ខ្លួនក្នុងការទទួលបាននូវការជំនុំជម្រះប្រកបដោយយុត្តិធម៌ ។ ជនជាប់ចោទរូបនេះបានបញ្ជាក់យ៉ាងច្បាស់ អំពីសិទ្ធរបស់ខ្លួនដែលអាចទទួលបាននូវសិទ្ធមួយចំនួនរួមមាន សិទ្ធទទួលបានការតំណាងឲ្យដោយមេធាវីការពារក្តី សិទ្ធទទួលបានការជូនដំណឹងអំពីការចោទប្រកាន់ និងយល់ពីបទចោទប្រកាន់ប្រឆាំងនឹងខ្លួន សិទ្ធក្នុងការជូនដំណឹងអំពីទីកន្លែងនិងការជិតមកដល់នៃការជំនុំជម្រះក្តីរបស់ខ្លួន សិទ្ធក្នុងការចូលរួមដោយខ្លួនឯងផ្ទាល់ សិទ្ធក្នុងការនៅស្ងៀមមិនឆ្លើយតបនៅគ្រប់សវនាការទាំងអស់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សិទ្ធទទួលបានការកាត់ក្តីដោយមានវត្តមានរបស់ជនជាប់ចោទ សិទ្ធក្នុងការសួរចម្លើយឬសុំឲ្យសួរចម្លើយទៅលើសាក្សីដាក់បន្ទុក និងសុំឲ្យមានវត្តមានសាក្សីទាំងនោះ សិទ្ធក្នុងការទទួលបាននូវពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារខ្លួន និងសិទ្ធទទួលបានការជំនុំជម្រះដោយមិនពន្យារពេល[១] ។ សិទ្ធមួយចំនួនខាងលើនេះ ជនជាប់ចោទបានផ្អែកទៅលើរដ្ឋធម្មនុញ្ញកម្ពុជា[២] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលា

---

[១] ការជូនដំណឹងរបស់លោក អៀង សារី ទៅលើអង្គជំនុំជម្រះសាលាដំបូងថាគាត់និងមិនផ្តល់សក្ខីកម្មទេ ថ្ងៃទី២៨ តុលា ឆ្នាំ២០១១ ដោយ ជនជាប់ចោទ អៀង សារី

[២] មាត្រា៣១ ៖ ព្រះរាជាណាចក្រកម្ពុជា ទទួលស្គាល់ និងគោរពសិទ្ធមនុស្ស ដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងនឹងសិទ្ធមនុស្ស សិទ្ធនារី និងសិទ្ធកុមារ ។

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់(.....) ។

Documentation Center of Cambodia
Searching for the Truth: Memory & Justice
ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌
66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
t (855-23) 211-875 ◆ f (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

ការកម្ពុជា[៣] វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះ[៤] និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធពលរដ្ឋ និងសិទ្ធនយោបាយ[៥] ។

ការធ្វើសេចក្តីជូនដំណឹងរបស់ជនជាប់ចោទ អៀង សារី គឺដើម្បីឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ។ សហព្រះរាជអាជ្ញា បានដាក់សំណើនេះក្នុងគោលបំណងដើម្បីឲ្យជនជាប់ចោទផ្តល់ព័ត៌មានទៅអង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀតអំពីចេតនាផ្តល់ភស្តុតាងដោយផ្ទាល់មាត់ ។ បន្ថែមទៅលើសំណើរបស់ខ្លួន នៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១១សហព្រះរាជអាជ្ញាបានដាក់សំណើបន្ថែមមួយទៀតក្នុងគោលបំណងចង់ឲ្យអង្គជំនុំជម្រះកំណត់ឲ្យមេធាវីការពារក្តីធ្វើការជូនដំណឹងដល់ភាគីទាំងអស់ឲ្យបានដឹងពីចេតនារបស់ជនជាប់ចោទនីមួយៗ នៅក្នុងការធ្វើសក្ខីកម្ម ។ ការដាក់សំណើបន្ថែមរបស់សហព្រះរាជអាជ្ញា គឺដើម្បីជំរុញឲ្យជនជាប់ចោទធ្វើការជូនដំណឹងឲ្យបានឆាប់រហ័ស ដោយបង្គាប់ឲ្យជនជាប់ចោទថ្លែងពីការសម្រេចចិត្តរបស់ខ្លួននៅក្នុងរយៈ

---

[៣] -មាត្រា៣៣ ៖ អង្គជំនុំជម្រះវិសាមញ្ញរបស់សាលាដំបូងត្រូវប្រព្រឹត្តឲ្យបានត្រឹមត្រូវ និងឆាប់រហ័សទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធរបស់ជនជាប់ចោទ(.....) ។

- មាត្រា៣៥ ៖ ជនជាប់ចោទណាក៏ដោយត្រូវទុកថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។ (....)

[៤] វិធាន២១(១)(ឃ) ៖ ជនណាដែលត្រូវសង្ស័យ ឬត្រូវបានចោទប្រកាន់ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនត្រូវបានរកឃើញ ។ ជនទាំងនេះមានសិទ្ធទទួលដំណឹងពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និងមានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេអំពីសិទ្ធនៅស្ងៀមមិនឆ្លើយតប ។

[៥] មាត្រា១៤ ៖ នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាដូចខាងក្រោម ៖

ក- ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន

ខ- មានពេលវេលាដើម្បីរៀបចំខ្លួន និងទាក់ទងជាមួយមេធាវីរបស់ខ្លួន

គ-ត្រូវទទួលបានការជំនុំជម្រះដោយគ្មានការអូសបន្លាយ

ឃ- ត្រូវបានការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីរបស់ខ្លួន

ង- ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុកក្នុងលក្ខខណ្ឌដូចគ្នានិងភស្តុតាងដាក់បន្ទុកដែរ

ច- មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនអាចនិយាយបាននូវភាសាដែលប្រើនៅក្នុងតុលាការ

ឆ- មិនត្រូវបានគេបង្ខំឲ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឲ្យឆ្លើយសារភាពថាមានកំហុស

ពេលចំនួនប្រាំពីរថ្ងៃ[៦] ។ ថេរវេលានេះ គិតចាប់ពីថ្ងៃចេញដីការបង្គាប់របស់អង្គជំនុំជម្រះ ។ ការជម្រុញរបស់សហព្រះរាជអាជ្ញា គឺដោយសារមូលហេតុពេលវេលានៃការចាប់ផ្តើមសវនាការលើអង្គសេចក្តីកាន់តែខិតចូលជិតមកដល់ហើយ ។ សវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ នឹងចាប់ផ្តើមប្រព្រឹត្តនៅថ្ងៃច័ន្ទ ទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ និងថ្ងៃបន្ទាប់[៧] នៅក្នុងបន្ទប់សវនាការធំនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានាវេលាម៉ោង ៩ព្រឹក ។ សហព្រះរាជអាជ្ញា បានបន្តទៀតគោលបំណងសំខាន់ គឺចង់ឲ្យភាគីទាំងអស់គួរតែបានជ្រាបអំពីចេតនារបស់ជនជាប់ចោទ ឲ្យបានមុនថ្ងៃចាប់ផ្តើមដំណើការនីតិវិធីលើអង្គសេចក្តីចាប់ផ្តើម ។ ជាចុងក្រោយសហព្រះរាជអាជ្ញា បានធ្វើការបញ្ចប់សំណើរបស់ខ្លួន ដោយរំលឹកដល់សហមេធាវី ក៏ដូចជាអង្គជំនុំជម្រះអំពីសារៈសំខាន់នៃការជូនដំណឹងរបស់ជនជាប់ចោទ ដែលចាំបាច់ក្នុងការកំណត់ពីរបៀបវារៈនៃសវនាការ ។

បន្ទាប់ពីការដាក់សំណើរបស់សហព្រះរាជអាជ្ញា និងការជូនដំណឹងរបស់ជនជាប់ចោទ អៀង សារី រួចមកអង្គជំនុំជម្រះសាលាដំបូងបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទ ។ ចម្លើយតបនេះ បានលើកឡើងអំពីការស្នើសុំរបស់សហព្រះរាជអាជ្ញា ដែលបានស្នើឲ្យអង្គជំនុំជម្រះបង្គាប់ទៅជនជាប់ចោទឲ្យដាក់សេចក្តីជូនដំណឹង អំពីការធ្វើសក្ខីកម្មនៅក្នុងសវនាការ ។ អង្គជំនុំជម្រះបានបញ្ជាក់អំពីសំដីរបស់សហព្រះរាជអាជ្ញានៅក្នុងចម្លើយតបរបស់ខ្លួនអំពីសិទ្ធរបស់ជនជាប់ចោទដែលអាចនៅស្ងៀមមិនឆ្លើយតបសំណួរក្នុងសវនាការ ។ អង្គជំនុំជម្រះបានបន្តបញ្ជាក់អំពីសំណើរបស់សហព្រះរាជអាជ្ញាចំពោះសិទ្ធរបស់ជនជាប់ចោទ នៅក្នុងករណីណាមួយដែលជនជាប់ចោទសម្រេចថាផ្តល់សក្ខីកម្មក្នុងអំឡុងពេលកិច្ចដំណើរការណីនីតិវិធី ខ្លួនត្រូវជូនដំណឹងជាមុនអំពីបញ្ហានេះដើម្បីផលប្រយោជន៍នៃការត្រៀមរៀបចំសវនាការប្រកបដោយប្រសិទ្ធភាព ។ អង្គជំនុំជម្រះសាលាដំបូងបានបន្តទៀតថា ដោយយោងតាមវិធាន៨៩ស្ទួន(២) នៃវិធានផ្ទៃក្នុង[៨] ខ្លួននឹងសួរសំណួរទៅជនជាប់ចោទ ។ អង្គជំនុំជម្រះ បានស្នើឲ្យសហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ថា នៅពេលដែលអង្គជំនុំជម្រះសួរសំនួរទៅជនជាប់ចោទនៅក្នុងសវនាការលើអង្គសេចក្តី ថ្ងៃទី២៨ ខែតុលា ឆ្នាំ

---

[៦] សំណើររបស់សហព្រះរាជអាជ្ញាសុំការអនុញ្ញាតដើម្បីឆ្លើយតប និងការឆ្លើយតបទៅនឹងចម្លើយតបរបស់ អៀង សារី ពាក់ព័ន្ធនឹងចេតនារបស់ជនជាប់ចោទ ទាក់ទងនឹងការផ្តល់សក្ខីកម្ម ថ្ងៃទី៣ ខែតុលា ឆ្នាំ២០១១ ដោយសហព្រះរាជអាជ្ញា

[៧] ដីការកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំនុំរឿង ០០២ ថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០១១ ដោយអង្គជំនុំជម្រះសាលាដំបូង

[៨] នៅមុនពេលសួរចម្លើយជនជាប់ចោទ សហព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានដោយសង្ខេបអំពីការចោទប្រកាន់ចំពោះជនជាប់ចោទ ។ ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទអាចធ្វើការឆ្លើយតបដោយសង្ខេបបាន ។

២០១១ ឬថ្ងៃបន្ទាប់ នាពេលខាងមុខនេះ ជនជាប់ចោទអាចឆ្លើយតបទៅនឹងសំនួរណាមួយ បន្ទាប់ពីបញ្ចប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់រួច ។ នៅក្នុងចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះបានបញ្ជាក់ប្រាប់ថា ខ្លួនបានឃើញសេចក្តីប្រានចោលការធ្វើសក្ខីកម្មរបស់ជនជាប់ចោទ អៀង សារី រួចហើយ ។ ជាចុងក្រោយ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា នៅក្នុងច្បាប់ដែលតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមកំពុងអនុវត្តជនជាប់ចោទអាចធ្វើការឆ្លើយតបទៅនឹងសំណួររបស់អង្គជំនុំជម្រះ ឬធ្វើសេចក្តីសន្និដ្ឋានបានប្រសិនបើខ្លួនមានបំណង ។